ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 12 / 09 / 2011
ម៉ោង (Time/Heure) : 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសង

**Case File/Dossier No. 002/19-09-2007/ECCC/TC**

| | |
|---|---|
| **នៅចំពោះមុខ :** | **ចៅក្រម និល ណុន, ប្រធាន** |
| | **ចៅក្រម Silvia CARTWRIGHT** |
| | **ចៅក្រម យ៉ា សុខន** |
| | **ចៅក្រម Jean-Marc LAVERGNE** |
| | **ចៅក្រម យូ អុតារា** |
| **កាលបរិច្ឆេទ :** | **ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១** |
| **ភាសាដើម :** | **ខ្មែរ/អង់គ្លេស/បារាំង** |
| **ចំណាត់ថ្នាក់:** | **សាធារណៈ** |

# សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម

| **សហព្រះរាជអាជ្ញា៖** | **ជនជាប់ចោទ៖** |
|---|---|
| ជា លាង | នួន ជា |
| Andrew CAYLEY | អៀង សារី |
| | អៀង ធីរិទ្ធ |
| | ខៀវ សំផន |

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីៈ**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**សហមេធាវីការពារក្តីៈ**
សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅស៊ាង
Diana ELLIS
ស សូវាន
Jaques VERGÈS

## ១. សេចក្តីផ្តើម

១. នៅក្នុងសវនាការបឋមលើសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ទឡ្ហីករណ៍ផ្ទាល់មាត់ទាក់ទងនឹងបញ្ហាទាំងអស់ ដែលអង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកថាជាអញ្ញត្រកម្មស្ថិតនៅក្នុងវិសាលភាពវិធាន ៨៩ នៃវិធានផ្ទៃក្នុង។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះក៏បានបញ្ជាក់ផងដែរថា ការបំភ្លឺបញ្ជាក់ទៅលើបញ្ហាផ្លូវច្បាប់មួយចំនួនទៀត ដែលភាគីនានាបានលើកឡើងក៏អាចជួយដល់ដំណើរការជំនុំជម្រះក្តីឱ្យមានភាពយុត្តិធម៌ និងភាពឆាប់រហ័សផងដែរ[១]។

២. នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ការិយាល័យសហព្រះរាជអាជ្ញាបានដាក់សំណើមួយសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ “JCE III” (ហៅថា ទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម) ជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសម្យ៉ាងទៀតនៅក្នុងសំណុំរឿង ០០២[២]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សារណាមួយច្បាប់ ដើម្បីជាការគាំទ្រដល់សំណើសុំរបស់សហព្រះរាជអាជ្ញា[៣]។ ក្រុមមេធាវីការពារក្តីទាំងអស់ បានជំទាស់ទៅនឹង

---

[១] ប្រតិចារិកសវនាការបឋម ពីថ្ងៃទី ២៧ ដល់ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០១១។

[២] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសម្យ៉ាងទៀត ឯកសារលេខ E100 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ (“សំណើសុំ”)។

[៣] សារណាគាំទ្រដល់សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសម្យ៉ាងទៀត ឯកសារលេខ E100/4 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។

សំណើសុំនេះ ដោយសំអាងទៅលើភាពអាចទទួលយកបាន និងអង្គសេចក្តីនៃសំណើសុំនេះ[៤]។ សហព្រះរាជអាជ្ញាបានដាក់ការឆ្លើយតបមួយនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១១[៥]។

៣. បន្ថែមលើនេះទៀត អង្គជំនុំជម្រះបានទទួលញត្តិមួយរបស់មេធាវីការពារក្តី អៀង សារី ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ដែលស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ ដោយសារកំហុសនីតិវិធី[៦]។ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងញត្តិនេះ នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១[៧]។

---

[៤] ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកទម្រង់ទី៣ នៃសហឧក្រិដ្ឋកម្មរួម (JCE III) ជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសម្យ៉ាងទៀត ឯកសារលេខ E100/1 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ("ចម្លើយតបរបស់ អៀង ធីរិទ្ធ")។ សារណាតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកទម្រង់ទី៣ នៃសហឧក្រិដ្ឋកម្មរួម ជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសម្យ៉ាងទៀត ឯកសារលេខ E100/5 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ("សារណាតបរបស់ នួន ជា")។ ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងទម្រង់ទី៣ នៃសហឧក្រិដ្ឋកម្មរួម ឯកសារលេខ E100/3 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ("សារណាតបរបស់ ខៀវ សំផន")។ ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកទម្រង់ទី៣ នៃសហឧក្រិដ្ឋកម្មរួម ថាជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសម្យ៉ាងទៀត និងសំណើសុំឱ្យមានសវនាការផ្ទាល់មាត់ ឯកសារលេខ E100/2 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ("ចម្លើយតបរបស់ អៀង សារី")។

[៥] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបនានារបស់មេធាវីការពារក្តី លើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកំណត់បទចោទនៅក្នុងដីកាដំណោះស្រាយជាថ្មីឡើងវិញ និងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីបទល្មើសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឯកសារ E95/6 ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១១ កថាខណ្ឌ ៨៣-៨៧។

[៦] "ញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសនីតិវិធី" ឯកសារលេខ E58, ចុះថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ៣-៦ ("ញត្តិរបស់អៀង សារី ស្នើសុំលុបចោល") ។ ក្នុងអញ្ញត្រកម្មរបស់ពួកគេ ជនជាប់ចោទ អៀង សារី, ខៀវ សំផន និងអៀង ធីរិទ្ធ បានដាក់សំណើពាក់ព័ន្ធ (សេចក្តីសង្ខេបបណ្តឹងអញ្ញត្រកម្ម របស់ អៀង សារី តាមវិធាន ៨៩ ឯកសារលេខ E514 ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១, កថាខណ្ឌ ២៤(ឃ), អញ្ញត្រកម្មលើយុត្តាធិការ ឯកសារលេខ E46 ចុះថ្ងៃទី១៤ ខែ កុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ១៨ ("អញ្ញត្រកម្មរបស់ ខៀវ សំផន") និង អញ្ញត្រកម្មរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ ឯកសារលេខ E44 ចុះថ្ងៃទី១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ៣៣-៣៨ ("អញ្ញត្រកម្មរបស់អៀង ធីរិទ្ធ") (ជារួម "ញត្តិរបស់មេធាវីការពារក្តី")។ សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបទៅនឹងអញ្ញត្រកម្មទាំងអស់របស់មេធាវីការពារក្តីនៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ និងថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១១ គឺ (ចម្លើយតបរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំពោះសារណារបស់ក្រុមភាគីការពារក្តីទាក់ទងនឹងអញ្ញត្រកម្ម (វិធាន ៨៩) ឯកសារលេខ E51/5/4 ចុះថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១១ កថាខណ្ឌ៤២-៥១ និងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្មរបស់មេធាវីការពារក្តី ដោយអនុលោមតាមវិធាន៨៩ ឯកសារលេខE51/5/3/1 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ កថាខណ្ឌ ២២-២៦)។

ក្នុងសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះក៏បានសម្រេចលើញត្តិ ត្រង់ផ្នែកទាំងឡាយណាដែលពាក់ព័ន្ធនឹងការអនុវត្តសហឧក្រិដ្ឋកម្មរួម[៨]។

## ២. ប្រវត្តិនីតិវិធី

៤. នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចមួយ ដោយលើកឡើងថា សហឧក្រិដ្ឋកម្មរួម អាចអនុវត្តបាននូវគ្រប់ទម្រង់របស់វា នៅចំពោះមុខ អ.វ.ត.ក[៩]។ នៅថ្ងៃទី ១៨ និងថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១០ មេធាវីការពារក្ដីបីក្រុមបានប្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចនេះ នៅចំពោះមុខអង្គបុរេជំនុំជម្រះ[១០]។ នៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១០ សហព្រះរាជអាជ្ញាបានដាក់សារណាឆ្លើយតបរួម ទៅនឹងសារណាតបរបស់មេធាវីការពារក្ដី ដោយលើក

---

[៧] "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិរបស់អៀង សារីស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសផ្នែកនីតិវិធី" ឯកសារលេខ E58/1, ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ កថាខណ្ឌ១-៧, ១៨-១៩ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិរបស់ អៀង សារី ស្នើសុំលុបចោល"។

[៨] *សូមមើលបន្ថែម* ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើផ្សេងៗ បន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការ ឯកសារលេខ E74, ចុះថ្ងៃទី៨ ខែ មេសា ឆ្នាំ ២០១១ ("អង្គជំនុំជម្រះបានទទួលនូវសំណើសុំជាច្រើន ទាក់ទងនឹងការជំទាស់ទៅលើការមិនអាចទទួលយកបាននូវផ្នែកខ្លះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ហានៅដំណាក់កាលស៊ើបអង្កេត [...រួមមានសំណើសុំដែល] ផ្នែកជាច្រើននៃដីកាត្រូវតែលុបចោល [....]។ វាមានភាពច្បាស់លាស់ដែលថាអង្គជំនុំជម្រះត្រូវជំនុំជម្រះទៅតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ [....] ប្រសិនបើមានភាពមិនច្បាស់លាស់នៅដំណាក់កាលនៃការជំនុំជម្រះ អង្គជំនុំជម្រះនឹងពិចារណាតាមករណីនីមួយៗ ដោយបកស្រាយអត្ថន័យនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយការបកស្រាយនេះនឹងចងកាតព្វកិច្ចអង្គជំនុំជម្រះ")។

[៩] ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម ឯកសារ D97/13 ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩។

[១០] បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការដាក់ឲ្យអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថា "សហឧក្រិដ្ឋកម្មរួម" ឯកសារលេខ D97/16/1, ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០។ បណ្ដឹងឧទ្ធរណ៍របស់មេធាវីអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចអំពីការអនុវត្តនៅអវតកនូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម ចេញថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារលេខ D/97/15/1, ចុះថ្ងៃទី១៨ ខែ មករា ឆ្នាំ ២០១០។ បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ក.ស.ច.ស អំពីការអនុវត្តនៅអ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម ឯកសារលេខ D97/14/5, ចុះថ្ងៃទី២២ ខែ មករា ឆ្នាំ២០១០។

ឡើងពីភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួមគ្រប់ទម្រង់ទាំងអស់ រួមទាំងសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ផងដែរ[១១]។

៥. នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ អង្គបុរេជំនុំជម្រះបានបដិសេធសំអាងហេតុរបស់សហព្រះរាជអាជ្ញានៅត្រង់ផ្នែកខ្លះ ដោយលើកឡើងថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ មិនបានបង្កើតទៅជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ ប៉ុន្តែតម្កល់ការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទី២[១២]។ ហេតុដូច្នេះហើយទើបដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ មិនបានដាក់បញ្ចូលសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ថាជាផ្នែកមួយនៃការទទួលខុសត្រូវប្រឆាំងនឹងជនជាប់ចោទណាម្នាក់នោះទេ ប៉ុន្តែបានចោទប្រកាន់ជនជាប់ចោទឱ្យទទួលខុសត្រូវ ដោយអនុលោមតាមការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ និង ទម្រង់ទី២[១៣]។

៦. សហព្រះរាជអាជ្ញាមិនបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការផាត់ចោល JCE ទម្រង់ទី៣ ចេញពីក្នុងដីកាដំណោះស្រាយ ដោយអនុលោមតាមវិធាន៦៧(៥) និង៧៤នោះទេ។ ក្នុងញត្តិរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះនេះ ជំនួសវិញ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងកំណត់បទចោទសាជាថ្មីក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសាលក្រម ក្នុងករណីសមស្របជាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ដោយអនុលោមតាម JCE ទម្រង់ទី៣ (ជាជាង JCE ទម្រង់ទី១ ឬទី២)[១៤]។

៧. មេធាវីការពារក្តីរបស់ អៀង សារី ជំទាស់ទៅនឹងការដាក់បញ្ចូលសហឧក្រិដ្ឋកម្មរួមក្នុងដីកាដំណោះស្រាយ ជាពិសេស អត្តសញ្ញាណនៃធាតុផ្សំរបស់វា ដែលតម្រូវឱ្យមានសម្រាប់ការចូលរួម

---

[១១] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និងខៀវ សំផន ស្តីអំពីសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២០១០ ឯកសារលេខD97/16/5។

[១២] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម។ អង្គបុរេជំនុំជម្រះ ឯកសារលេខ D97/15/9 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៦៩, ៧៧,៨៨ ("សាលដីកា អ.ប.ជ សម្រេចអំពីសហឧក្រិដ្ឋកម្មរួម")។

[១៣] ដីកាដំណោះស្រាយ ឯកសារលេខ D427 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ (ដូចដែលបានកែប្រែតាមរយៈសាលដីការបស់អង្គបុរេជំនុំជម្រះសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/3/15 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ និង សាលដីការបស់អង្គបុរេជំនុំជម្រះសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១) ("ដីកាដំណោះស្រាយដែលបានកែប្រែ")។

[១៤] ញត្តិរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១។

ក្នុងផែនការឧក្រិដ្ឋកម្មរួមមួយ និងការប្រព្រឹត្តចំពោះលក្ខខណ្ឌតម្រូវនៃចេតនាជាក់លាក់ទាក់ទិននឹងអំពើប្រល័យពូជសាសន៍[១៥]។

## ៣. សារៈណានានា

### ៣.១. ញត្តិរបស់មេធាវីការពារក្តី

៨. មេធាវីការពារក្តី អៀង សារី គូសបញ្ជាក់ថា ដីកាដំណោះស្រាយខកខានមិនបានយកមកអនុវត្តឲ្យបានត្រឹមត្រូវនូវ*ធាតុផ្សំអត្តនោម័ត* (*mens rea*) ទាក់ទងនឹងការចូលរួមរបស់លោក អៀង សារី ក្នុងផែនការឧក្រិដ្ឋកម្មរួមនោះទេ[១៦]។ ដីកាដំណោះស្រាយចោទប្រកាន់ថា គាត់បានចូលរួមក្នុងផែនការមិនមែនជាឧក្រិដ្ឋកម្មរួមមួយ ដែលជាក់ច្បាស់ថា បណ្តាលឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋនានា។ ការចោទប្រកាន់បែបនេះ ប្រសិនបើមានភស្តុតាងគាំទ្រច្បាស់លាស់នោះ គឺមិនគាំទ្រដល់*ភស្តុតាងបឋម* (*prima facie*) នៃ JCE ទម្រង់ទី១ឡើយ។ បន្ថែមលើនេះទៀត គាត់គូសបញ្ជាក់ថា JCE ពេលត្រូវបានអនុវត្តចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទាមទារនូវភស្តុតាងនៃចេតនាជាក់លាក់ (ដូចជា ចេតនាក្នុងការកម្ទេចទាំងស្រុង ឬជាផ្នែក នូវក្រុមសាសនា ជាតិពន្ធុ ជាតិសាសន៍ ឬជនជាតិ)[១៧]។ ដោយសារដីកាដំណោះស្រាយគ្រាន់តែចោទប្រកាន់ថា សមាជិក JCE ដឹងអំពីចេតនាប្រល័យពូជសាសន៍របស់ថារី ប៉ុន្តែមិនបញ្ជាក់ថា អៀង សារី បានរួមចំណែកក្នុងចេតនាប្រល័យពូជសាសន៍នេះទេ រាល់ការយោងទាំងអស់ទាក់ទិននឹងអំពើប្រល័យពូជសាសន៍ត្រូវតែលុបចេញឲ្យអស់ពីដីកានេះ[១៨]។

៩. បើទោះជាទទួលស្គាល់ថា JCE ទម្រង់ទី១ ជាចំណែកដ៏ជាក់ច្បាស់នៃច្បាប់កម្ពុជានៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ក្តី ក៏មេធាវីការពារក្តី អៀង ធីរិទ្ធ គូសបញ្ជាក់ថា JCE ទម្រង់ទី២ មានលក្ខណៈស្រពេចស្រពិល និងមិនជាក់ច្បាស់ ដូច្នេះហើយ មិនអាចអនុវត្តទៅបាននៅចំពោះមុខ អ.វ.ត.ក នោះទេ[១៩]។

---

[១៥] ញត្តិរបស់ អៀង សារី ស្នើសុំឲ្យលុបចោល កថាខណ្ឌ២០-២៨។

[១៦] ញត្តិរបស់ អៀង សារី ស្នើសុំឲ្យលុបចោល កថាខណ្ឌ២០។

[១៧] ញត្តិរបស់ អៀង សារី ស្នើសុំឲ្យលុបចោល កថាខណ្ឌ២១-២៤។

[១៨] ញត្តិរបស់ អៀង សារី ស្នើសុំឲ្យលុបចោល កថាខណ្ឌ២៦-២៨។

[១៩] បណ្តឹងអញ្ញត្រកម្មរបស់ អៀង ធីរិទ្ធ កថាខណ្ឌ៣៦-៣៧ (ដោយហេតុថា ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ រាប់បញ្ចូលសហប្រព្រឹត្តកម្ម និងការចូលដៃ ដែលទោះយ៉ាងណាក្តី "ត្រួតស៊ីគ្នាយ៉ាងខ្លាំងនឹងសហឧក្រិដ្ឋកម្មរួម ក្នុងទម្រង់មូលដ្ឋាន និង

១០. សហព្រះរាជអាជ្ញាគូសបញ្ជាក់ថា អៀង សារី បកស្រាយដីកាដំណោះស្រាយខុស ហើយថា អង្គហេតុនានា ដែលបានដាក់បញ្ចូលក្នុងដីកាដំណោះស្រាយគាំទ្រដល់សេចក្តីសន្និដ្ឋាន ដែលថា អៀង សារី បានចូលរួមចំណែកដោយចេតនា ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម តាមរយៈសហឧក្រិដ្ឋកម្មរួម[២០]។ ពួកគាត់គូសបញ្ជាក់ថា JCE ក្នុងគ្រប់ទម្រង់របស់វា ត្រូវបានចាត់ទុកជាទម្រង់នៃការទទួលខុសត្រូវឧក្រិដ្ឋកម្ម ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងពេលវេលាពាក់ព័ន្ធនឹងសំណុំរឿង ០០២[២១]។

## ៣.២. ញត្តិរបស់សហព្រះរាជអាជ្ញា

### ៣.២.១. *ភាពអាចទទួលយកបាន*

១១. ក្រុមមេធាវីការពារក្តីទាំងអស់ជំទាស់ថា សំណើរបស់សហព្រះរាជអាជ្ញាមិនអាចទទួលយកបានទេ ដោយសារសំណើសុំនេះគឺជាសំណើសុំអំពីការជំទាស់ផ្នែកយុត្តាធិការ ដោយអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង ហើយកាលបរិច្ឆេទចុងក្រោយសម្រាប់ការដាក់អញ្ញត្រកម្ម បានកន្លងផុតទៅជាយូរមកហើយ[២២]។

១២. សហព្រះរាជអាជ្ញាលើកឡើងថា ដោយអនុលោមតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង សំណើសុំរបស់ខ្លួនអាចទទួលយកបាន[២៣]។ វិធាននេះអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូង ផ្លាស់ប្តូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ សហព្រះរាជអាជ្ញាយល់ឃើញថា ការកំណត់បទចោទជាថ្មីឡើងវិញនេះ គឺស្របទៅនឹងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទ ពីព្រោះជនជាប់ចោទបានទទួលព័ត៌មានអំពីចេតនារបស់សហ

---

ទម្រង់ទី២របស់វា") សូមមើលផងដែរ បណ្តឹងអញ្ញត្រកម្មរបស់ ខៀវ សំផន កថាខណ្ឌ ១៨ (ដែលទទួលយកដោយយោងទៅញត្តិរបស់ អៀង សារី នៅចំពោះមុខអង្គបុរេជំនុំជម្រះ)។

[២០] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិរបស់ អៀង សារី ស្នើសុំឱ្យលុបចោល, កថាខណ្ឌ៣២-៣៦។

[២១] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងអញ្ញត្រកម្មក្រុមការពារក្តី តាមវិធាន ៨៩, ឯកសារលេខ E51/5/3/1, ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១, កថាខណ្ឌ២៣-២៦ (ដាក់បញ្ចូលដោយយោងនូវសារណាមុនៗ)។

[២២] ចម្លើយតបរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ៣ និងកថាខណ្ឌ ៧-១០។ ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ៣។ ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ២៦។ ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ៤។ សូមមើលផងដែរ សំណើរបស់ អៀង សារី សុំឱ្យមានសេចក្តីសម្រេចជាបន្ទាន់ទាក់ទងនឹងបញ្ហាថា តើសហព្រះរាជអាជ្ញាអាចស្នើសុំឱ្យផ្លាស់ប្តូរការកំណត់បទចោទ នៅដំណាក់កាលនេះនៃនីតិវិធី ដែរឬអត់, ឯកសារ E103 ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១។

[២៣] សំណើសុំរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨។

ព្រះរាជអាជ្ញា ក្នុងការស្នើសុំឱ្យកំណត់បទចោទជាថ្មីឡើងវិញ និងដោយសារភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ត្រូវបានជជែកតវ៉ាយ៉ាងល្អិតល្អន់ នៅដំណាក់កាលមុនការជំនុំជម្រះរួចហើយ[២៤]។ សហព្រះរាជអាជ្ញាក៏បានកត់សម្គាល់ផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានទទួលយល់ព្រមតាមសំណើសុំស្រដៀងគ្នានេះ នៅក្នុងសំណុំរឿង ០០១[២៥]។

៣.២.២. *អង្គសេចក្តី*

១៣. នៅក្នុងសំណើសុំរបស់ខ្លួន សហព្រះរាជអាជ្ញា បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តតាមវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) នៅក្នុងរឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង Tadić* ពាក់ព័ន្ធនឹងភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣[២៦]។ ទាក់ទងទៅនឹងវិធីសាស្ត្រនេះ សហព្រះរាជអាជ្ញាបានសំអាងជាក់លាក់ទៅលើរឿងក្តីចំនួនពីរ ដែលបានលើកឡើងនៅក្នុងសាលដីកាសម្រេចលើរឿងក្តីរបស់ *Tadić*៖ *រឿងក្តីសម្លាប់ដោយហ្វូងមនុស្សនៅទីក្រុង Essen* ចំពោះការជំនុំជម្រះទៅលើឧក្រិដ្ឋជនសង្គ្រាមតុលាការយោធាអង់គ្លេស និង*រឿងក្តីនៅកោះ Borkum* ដែលជំនុំជម្រះដោយតុលាការយោធាអាមេរិកនៅទីក្រុង Dachau[២៧]។ ជាជម្រើស សហព្រះរាជអាជ្ញាក៏បានជំទាស់តវ៉ាថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ បង្កើតបានជាគោលការណ៍ទូទៅនៃច្បាប់ និងអាចយកមកអនុវត្តបានដោយយោងទៅលើមូលដ្ឋាននេះតែម្តង[២៨]។

១៤. មេធាវីការពារក្តីបីក្រុមជំទាស់ថា ប្រភពច្បាប់ទាំងឡាយដែលបានយកមកសំអាងនៅក្នុងសាលដីកាសម្រេចលើរឿងក្តី *Tadić* មិនគាំទ្រដល់អត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ថាជាទម្រង់នៃ

---

[២៤] សំណើសុំរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៩-១១។

[២៥] សំណើសុំរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨ *ដែលបានយោង* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ឯកសារលេខ E188 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ("សាលក្រមសម្រេចលើរឿងក្តីរបស់ *ឌុច*") កថាខណ្ឌ ៤៩០ និងកថាខណ្ឌ ៥១៦។

[២៦] សំណើសុំរបស់សហព្រះរាជអាជ្ញាស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ២០-២១។ រឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿងលេខ IT-94-1-A) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ ("សាលដីកាសម្រេចលើរឿងក្តីរបស់ *Tadić*")។

[២៧] សំណើសុំរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៤-២៨។

[២៨] សំណើសុំរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៩-៣០។

ការទទួលខុសត្រូវនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ[២៩]។ មេធាវីការពារក្តីពីរក្រុមក៏ជំទាស់ថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ មិនមែនជាគោលការណ៍ទូទៅនៃច្បាប់ទេ[៣០]។ មេធាវីការពារក្តីរបស់ អៀង សារី ក៏បានកត់សម្គាល់បន្ថែមទៀតថា សាលដីកាសម្រេចលើរឿងក្តី *Tadić* ផ្ទាល់បានលើកឡើងថា ប្រភពច្បាប់ក្នុងស្រុក មិនគួរត្រូវបានយកមកធ្វើជាសំអាង ថាជាភស្តុតាងមិនអាចបដិសេធបានដែលថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ បង្កើតបានជាគោលការណ៍ទូទៅនៃច្បាប់នោះទេ[៣១]។

## ៤. ការពិភាក្សាសម្រេច

### ៤.១ សេចក្តីផ្តើម

១៥. សហឧក្រិដ្ឋកម្មរួម ត្រូវបានកំណត់ឡើងជាលើកដំបូង ដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY នៅក្នុងសាលដីកាសម្រេចលើរឿងក្តីរបស់ *Tadić* ក្នុងឆ្នាំ ១៩៩៩។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថា ការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម បង្កបានជាទម្រង់នៃការទទួលខុសត្រូវ ក្នុងទម្រង់ជាការប្រព្រឹត្តបទល្មើស[៣២]។ ទាំងអង្គបុរេជំនុំជម្រះ និងទាំងអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានយល់ឃើញប្រហាក់ប្រហែលគ្នាថា ការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម បង្កបានជាការប្រព្រឹត្តដែលស្ថិតនៅក្នុងវិសាលភាពមាត្រា ២៩ (ថ្មី) នៃច្បាប់ អ.វ.ត.ក[៣៣]។ សហឧក្រិដ្ឋកម្មរួមទាំងបីទម្រង់ ដែលបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសាលដីកាសម្រេចលើរឿងក្តីរបស់ *Tadić* រួមមាន៖

- ទម្រង់ជាមូលដ្ឋាន ឬសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ គឺពាក់ព័ន្ធនឹងករណីទាំងឡាយដែលអ្នកចូលរួមទាំងអស់ធ្វើសកម្មភាពទៅតាមគោលបំណងរួមមួយ និងមានចេតនាឧក្រិដ្ឋដូចគ្នា[៣៤]។

---

[២៩] ចម្លើយតបរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ កថាខណ្ឌ ១៩។ សារណាឆ្លើយតបរបស់មេធាវីការពារក្តី នួន ជា កថាខណ្ឌ ៨។ ចម្លើយតបរបស់មេធាវីការពារក្តី អៀង សារី កថាខណ្ឌ ៩-១៧។ មេធាវីការពារក្តីរបស់ ខៀវ សំផន សំអាងទាំងស្រុងទៅលើទឡ្ហីករណ៍របស់ខ្លួន ទាក់ទងទៅនឹងភាពមិនអាចទទួលយកបាននៃញត្តិរបស់សហព្រះរាជអាជ្ញា។

[៣០] ចម្លើយតបរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ កថាខណ្ឌ ២០។ ចម្លើយតបរបស់មេធាវីការពារក្តី អៀង សារី កថាខណ្ឌ ១៩-២១។

[៣១] ចម្លើយតបរបស់មេធាវីការពារក្តី អៀង សារី កថាខណ្ឌ ១៩។

[៣២] សាលដីកាសម្រេចលើរឿងក្តីរបស់ *Tadić* កថាខណ្ឌ ១៩០។

[៣៣] សាលដីកា អ.ប.ជ សម្រេចអំពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៤៩។ សាលក្រមសម្រេចលើរឿងក្តីរបស់ *ឌុច* កថាខណ្ឌ ៥១១។

[៣៤] សាលដីកាសម្រេចលើរឿងក្តីរបស់ *Tadić* កថាខណ្ឌ ១៩៦ ដល់ ២០១។

- ទម្រង់ជាប្រព័ន្ធ ឬសហឧក្រិដ្ឋកម្មរួមទម្រង់ទី២ គឺសំដៅទៅលើករណីនៃការប្រព្រឹត្តដោយអមនុស្សធម៌ជាប្រព័ន្ធ នៅក្នុងស្ថាប័នដែលមានរចនាសម្ព័ន្ធចាត់តាំង ដូចជា ជំរំប្រមូលផ្តុំ[៣៥] និង
- ទម្រង់ទូលាយ ឬសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ គឺពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់សមាជិកនៃក្រុមនោះ ចំពោះអំពើដែលកើតឡើងដោយសារផលវិបាកជាធម្មតា និងដែលអាចប្រមើលដឹងជាមុនបាន ពីការបំពេញគោលបំណងរួមរបស់ក្រុមនោះ[៣៦]។ ដើម្បីរកឱ្យឃើញថា វាជាការទទួលខុសត្រូវនៅក្រោមទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួមនេះ គេត្រូវបង្ហាញថា ជនជាប់ចោទមានបំណងចូលរួមនៅក្នុងសកម្មភាពល្មើស និងធ្វើសកម្មភាពល្មើសរបស់ក្រុមបន្ថែមទៀត និងចូលរួមចំណែកដល់សហឧក្រិដ្ឋកម្មរួមរបស់ក្រុមនោះ។ គេក៏ត្រូវបង្ហាញឱ្យឃើញផងដែរថា វាជាការអាចប្រមើលដឹងជាមុនបានថា បទល្មើសមួយដែលស្ថិតនៅខាងក្រៅវិសាលភាពនៃការព្រមព្រៀងនេះ អាចត្រូវបានប្រព្រឹត្តឡើងដោយសមាជិកម្នាក់ ឬច្រើននាក់របស់ក្រុម ហើយជនជាប់ចោទបានទទួលយកហានិភ័យដោយឆន្ទៈ ដែលថា ហានិភ័យនេះអាចនឹងកើតឡើង[៣៧]។

## ៤.២ លក្ខខណ្ឌតម្រូវនៃការបញ្ជូនរឿងទៅជំនុំជម្រះទាក់ទិននឹងសហឧក្រិដ្ឋកម្មរួម

### *៤.២.១. ច្បាប់ជាធរមាន*

១៦. ក្នុងករណីទាក់ទិននឹងចេតនាជាក់លាក់នោះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ភស្តុតាងត្រូវតែបង្ហាញជាចាំបាច់ថា ជនជាប់ចោទមិនត្រឹមតែមានចេតនាក្នុងការប្រព្រឹត្តបទល្មើសដែលចោទមកនោះប៉ុណ្ណោះទេ ប៉ុន្តែពួកគេថែមទាំងមានចេតនាពិសេសដែលជាលក្ខខណ្ឌតម្រូវដោយបទល្មើសទាំងនេះផងដែរ[៣៨]។ ដើម្បីផ្តន្ទាទោសចំពោះអំពើប្រល័យពូជសាសន៍ដែលប្រព្រឹត្តឡើងជាផ្នែកមួយនៃ

---

[៣៥] សាលដីកាសម្រេចលើរឿងក្តីរបស់ *Tadić* កថាខណ្ឌ ២០២ ដល់ ២០៣។

[៣៦] សាលដីកាសម្រេចលើរឿងក្តីរបស់ *Tadić* កថាខណ្ឌ ២០៤។

[៣៧] សាលដីកាសម្រេចលើរឿងក្តីរបស់ *Tadić* កថាខណ្ឌ ២២៨។

[៣៨] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Simba,* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (សំណុំរឿងលេខ ICTR-01-76-T), ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥ (" សាលក្រមសាលាដំបូងក្នុងរឿងក្តី *Simba*"), កថាខណ្ឌ ៣៨៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Munyakazi,* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (សំណុំរឿងលេខ ICTR-97-36A-T), ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១០, ("សាលក្រមសាលាដំបូងក្នុងរឿងក្តី *Munyakazi* "), កថាខណ្ឌ 439។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកដទៃទៀត,* សាលក្រមសាលាដំបូង, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (សំណុំរឿងលេខ IT-98-30/1-T), ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០០១. កថាខណ្ឌ 288។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកដទៃទៀត,* សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿងលេខ IT-98-30/1-A), ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥

សហឧក្រិដ្ឋកម្មរួមបាន វាជាការចាំបាច់ដែលគេត្រូវតែបង្ហាញភស្តុតាងថា ជនជាប់ចោទមានចេតនាក្នុងការបំផ្លាញទាំងស្រុង ឬផ្នែកមួយនៃក្រុមណាមួយដែលត្រូវបានការពារ[៣៩]។ ទោះជាយ៉ាងណាក្តី ភស្តុតាងនៃចេតនាចំពោះអំពើប្រល័យពូជសាសន៍ អាចត្រូវបានបង្ហាញ ដោយផ្អែកលើភស្តុតាងប្រយោល នៅពេលវាជាសេចក្តីសន្និដ្ឋានសមហេតុផលតែមួយគត់ ទៅតាមស្ថានភាពនៃរឿងក្តី[៤០]។

១៧. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់បន្ថែមទៀតថា សហឧក្រិដ្ឋកម្មរួមគឺជាទម្រង់មួយនៃការទទួលខុសត្រូវ និងមិនមែនជាបទឧក្រិដ្ឋនោះទេ។ ក្នុងន័យនេះ វាជាការគ្រប់គ្រាន់ក្នុងការបង្ហាញថា ជនជាប់ចោទបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមតាមវិធីណាមួយ ហើយថា ការចូលរួមនេះស្មើនឹងការប្រព្រឹត្ត ឬពាក់ព័ន្ធនឹងការប្រព្រឹត្តបទឧក្រិដ្ឋណាមួយ[៤១]។ ច្បាប់យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិបានសម្រេចយ៉ាងស៊ីសង្វាក់គ្នាថា ផែនការរួមដែលបានបង្កើតជាសហឧក្រិដ្ឋកម្មរួមពុំចាំបាច់មានលក្ខណៈឧក្រិដ្ឋនោះទេ ល្គឹកណាបទល្មើសត្រូវបានពិចារណាថាជាមធ្យោបាយមួយក្នុងការនាំឲ្យផែនការរួមសម្រេចចេញជាផល[៤២]។ ចំពោះបណ្តឹងឧទ្ធរណ៍នៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ("SCSL") ក្នុង *រឿងក្តី Brima និងអ្នកដទៃទៀត* មេធាវីការពារក្តីបានលើកជាទឡ្ហីករណ៍ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានវិការៈ ដោយសារផែនការរួមដែលត្រូវបានចោទ

---

("សាលដីកាសាលាឧទ្ធរណ៍ក្នុងរឿងក្រី *Kvočka*"), កថាខណ្ឌ 240-45។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krnojelac,* សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿងលេខ IT-97-25-A), ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣, កថាខណ្ឌ 111។

[៣៩] សាលក្រមសាលាដំបូងក្នុងរឿងក្តី *Simba*, កថាខណ្ឌ 415-419។ សាលក្រមសាលាដំបូងក្នុងរឿងក្តី *Munyakazi*, កថាខណ្ឌ 500-501។

[៤០] សាលក្រមសាលាដំបូងក្នុងរឿងក្តី *Simba*, កថាខណ្ឌ 415-419។ សាលក្រមសាលាដំបូងក្នុងរឿងក្តី *Munyakazi*, កថាខណ្ឌ 500-501។

[៤១] សាលដីកាសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Tadic*, កថាខណ្ឌ 227។ សាលដីកាសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Kvočka*, កថាខណ្ឌ 46។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krnojelac,* សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿងលេខ IT-97-25-A), ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣, កថាខណ្ឌ 31។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ntakirutimana,* សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR (សំណុំរឿងលេខ ICTR-96-10-A និង ICTR-96-17-A), ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤, កថាខណ្ឌ 466។

[៤២] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brima et. al.,* សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ SCSL (សំណុំរឿងលេខ SCSL-04-16-A), ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨, ("សាលដីកាសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Brima*"), កថាខណ្ឌ 80។

ប្រកាន់មិនមែនជាបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិនោះទេ[៤៣]។ ដោយកត់សម្គាល់នូវរឿងក្តីជាច្រើនទៀតពីតុលាការ ICTY និងលក្ខន្តិកៈទីក្រុងរ៉ូមនោះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ SCSL បានសម្រេចថា ផែនការរួម ការរៀបចំ និងគោលបំណងនៃសហឧក្រិដ្ឋកម្មរួមត្រូវតែមានកម្មវត្ថុជាបទឧក្រិដ្ឋ ឬរៀបចំបទឧក្រិដ្ឋជាមធ្យោបាយនៃការសម្រេចឱ្យបានតាមគោលដៅរបស់វា[៤៤]។ អង្គជំនុំជម្រះនេះបានសន្និដ្ឋានថា "ទោះបីគោលដៅដើម្បីទទួលបាន និងអនុវត្តអំណាចនយោបាយ និងការត្រួតត្រាលើទឹកដីនៃប្រទេសសេរ៉ាឡេអូន មិនមែនជាបទឧក្រិដ្ឋតាមលក្ខន្តិកៈនេះក៏ដោយ តែសកម្មភាពដែលបានរៀបចំឡើង ជាមធ្យោបាយក្នុងការសម្រេចឱ្យបាននូវគោលដៅនោះជាបទឧក្រិដ្ឋដែលមានចែងក្នុងលក្ខន្តិកៈនេះ"[៤៥]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Kvočka* នៃតុលាការ ICTY បានកត់សម្គាល់ស្រដៀងគ្នានេះដែរថា មូលដ្ឋានគ្រឹះនៃការចោទប្រកាន់ក្នុងរឿងក្តីនេះ ទាក់ទិននឹងសហឧក្រិដ្ឋកម្មរួមគឺជាគោលបំណងរួមនៃ "ការបង្កើតរដ្ឋស៊ែបនៅក្នុងអតីតប្រទេសយូហ្គោស្លាវី"[៤៦]។ អាស្រ័យហេតុនេះ ផែនការរួម ការរៀបចំ ឬគោលបំណងនៃសហឧក្រិដ្ឋកម្មរួមមួយត្រូវតែមានគោលដៅរបស់វាជាបទល្មើសមួយ ឬមានការពិចារណាលើបទល្មើសថាជាមធ្យោបាយមួយក្នុងការសម្រេចគោលដៅរបស់វា។ ផែនការរួមដោយផ្ទាល់ពុំចាំបាច់មានលក្ខណៈឧក្រិដ្ឋនោះទេ។

### *៤.២.២. ប្រព្រឹត្តិកម្មទៅលើគោលបំណងរួម និងធាតុផ្សំអត្តនោម័តសម្រាប់សហឧក្រិដ្ឋកម្មរួម នៅក្នុងដីកាដំណោះស្រាយ*

១៨. ទាក់ទិននឹងចរិតលក្ខណៈនៃផែនការរួមដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង០០២នោះ ដីកាដំណោះស្រាយបានលើកឡើងថា៖

> ផែនការរួមរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា គឺធ្វើឱ្យសម្រេចបាននូវបដិវត្តន៍សង្គមនិយមឆាប់រហ័សនៅកម្ពុជា តាម "ជំហានមហាលោតផ្លោះ" និងការការពារប្រទេសប្រឆាំងទៅនឹងសត្រូវទាំងខាងក្នុង និងខាងក្រៅ តាមគ្រប់មធ្យោបាយចាំបាច់។ ផែនការរួមនេះពុំមែនមាន

---

[៤៣] សាលដីកាសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Brima*, កថាខណ្ឌ 71។ សាលដីកាសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Kvočka*, កថាខណ្ឌ 46។

[៤៤] សាលដីកាសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Brima*, កថាខណ្ឌ 77-80។

[៤៥] សាលដីកាសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Brima*, កថាខណ្ឌ 84។

[៤៦] សាលដីកាសាលាឧទ្ធរណ៍ *Kvočka*, កថាខណ្ឌ 46 (ដែលបានសន្និដ្ឋានថា រដ្ឋអាជ្ញាបានផ្តល់ការចាប់អារម្មណ៍យ៉ាងច្បាស់ និងស៊ីសង្វាក់គ្នាថា ខ្លួនមានបំណងពឹងផ្អែកលើទ្រឹស្តីសហឧក្រិដ្ឋកម្មរួម និងបានច្រានចោលនូវមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ដែលបានដាក់)។

លក្ខណៈឧក្រិដ្ឋទាំងស្រុងនោះទេ ប៉ុន្តែការធ្វើឱ្យសម្រេចផែនការរួមនេះរួមមាន ជាការប្រព្រឹត្តនូវឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ឬក៏ជាការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ[៤៧]។

១៩. ទោះបីតាមន័យធម្មតានៃកថាខណ្ឌនេះអះអាងបញ្ជាក់ថា គោលបំណងនៃផែនការរួមពុំមែនមានលក្ខណៈឧក្រិដ្ឋទាំងស្រុងនោះក៏ដោយ តែវាបានបញ្ជាក់ច្បាស់ថា ការអនុវត្តផែនការរួមនោះគឺពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ ជាងនេះទៀត កថាខណ្ឌបន្ទាប់នៃដីកាដំណោះស្រាយបង្ហាញពីសកម្មភាពល្មើសមួយចំនួនដែល "នាំឱ្យមាន" ឬ "ត្រូវបានប្រព្រឹត្តដោយសមាជិករបស់សហឧក្រិដ្ឋកម្មរួម ព្រមទាំងបុគ្គលនានាដែលមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម"[៤៨]។ ពាក្យពេចន៍នេះបង្ហាញឱ្យឃើញច្បាស់ថា ផែនការនោះពាក់ព័ន្ធនឹងការប្រព្រឹត្តអំពីឧក្រិដ្ឋរបស់សមាជិកសហឧក្រិដ្ឋកម្មរួម។ ពាក្យពេចន៍នេះស្របទៅនឹងករណីយុត្តិសាស្ត្រខាងលើ និងមិនបានគាំទ្រដល់ការសន្និដ្ឋានដែលថា អៀង សារី ត្រូវបានចោទប្រកាន់ដោយគ្រាន់តែការចូលរួមក្នុងផែនការរួមដែលមិនមានលក្ខណៈឧក្រិដ្ឋនោះទេ។

២០. ទាក់ទិននឹងចេតនាឧក្រិដ្ឋចំពោះអំពើប្រល័យពូជសាសន៍ ដែលចោទប្រកាន់ចំពោះជនជាប់ចោទថាជាអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមនោះ ដីកាដំណោះស្រាយដែលត្រូវបានកែប្រែអះអាងថា៖

> ទាក់ទងដល់គោលនយោបាយប្រឆាំងនឹងជនជាតិចាម និងជនជាតិវៀតណាម ផែនការក្នុងការកម្ទេចមនុស្សអស់ទាំងនេះបានកើតឡើងចាប់តាំងពីខែ មេសា ឆ្នាំ ១៩៧៧ ចំពោះជនជាតិវៀតណាម និងចាប់តាំងពីដើមឆ្នាំ ១៩៧៧ ចំពោះជនជាតិចាម។ បន្ទាប់ពីនោះមក សមាជិកទាំងឡាយនៃសហឧក្រិដ្ឋកម្មរួមបានដឹងអំពីការណ៍ដែលថា ការធ្វើឱ្យបានសម្រេចនូវផែនការរួមត្រូវបានពន្លាតផងដែរ ដល់ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទៅលើក្រុមមនុស្សដែលទទួលបានការការពារទាំងនេះ។ ការណ៍ដែលថា សមាជិកទាំងឡាយនៃសហឧក្រិដ្ឋកម្មរួមទទួលយកការបង្កើតមធ្យោបាយប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលមធ្យោបាយនេះត្រូវបានប្រើប្រាស់ដើម្បីធ្វើឱ្យបានសម្រេចនូវផែនការរួម មានន័យថា សមាជិកទាំងនេះមានចេតនាក្នុងការធ្វើឱ្យសម្រេចនូវផែនការនោះ តាមរយៈអំពើប្រល័យពូជសាសន៍[៤៩]។

---

[៤៧] ដីកាដំណោះស្រាយដែលត្រូវបានកែប្រែ, កថាខណ្ឌ 1524។

[៤៨] ដីកាដំណោះស្រាយដែលត្រូវបានកែប្រែ, កថាខណ្ឌ 1525។

[៤៩] ដីកាដំណោះស្រាយដែលត្រូវបានកែប្រែ, កថាខណ្ឌ 1527។

២១. ជាងនេះទៀត ពីកថាខណ្ឌ ១៥៣២ ដល់កថាខណ្ឌ ១៥៤១ នៃដីកាដំណោះស្រាយដែលត្រូវបានកែប្រែ បានកំណត់ថា ទង្វើរបស់ជនជាប់ចោទ និងការចូលរួមរបស់ពួកគេស្ថិតក្នុងសហឧក្រិដ្ឋកម្មរួម។ ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់ ទង្វើនេះអាចនាំឲ្យមានការសន្និដ្ឋានថា ជនជាប់ចោទមានចេតនាពិសេស ចាំបាច់ដល់ការបង្ហាញពីអំពើប្រល័យពូជសាសន៍បាន[៥០]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា នៅពេលអានដីកាដំណោះស្រាយដែលត្រូវបានកែប្រែទាំងមូល កថាខណ្ឌ ១៥២៧ មិនអនុវត្តធាតុអត្តនោម័តដែលមិនត្រឹមត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលត្រូវបានប្រព្រឹត្តជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួមទេ។

### ៤.៣. ភាពអាចអនុវត្តបាននៃទម្រង់ទី១ និងទម្រង់ទី២ នៃសហឧក្រិដ្ឋកម្មរួម

២២. នៅក្នុងសាលក្រមរឿងក្តី ឌុច ចៅក្រមបានរកឃើញថា សញ្ញាណនៃការប្រព្រឹត្តតាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម គឺស្ថិតនៅក្នុងវិសាលភាពនៃមាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[៥១]។ នៅក្នុងសាលក្រមនេះ ចៅក្រមក៏សម្រេចបន្ថែមផងដែរថា ទម្រង់ជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួម រួមទាំងទម្រង់មូលដ្ឋាន ដែលបង្កើតឲ្យមានទម្រង់ជាប្រព័ន្ធនេះផងដែរ (ដូចជាទម្រង់ទី១ និងទម្រង់ទី២) គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩[៥២]។ ភាពអាចអនុវត្តបាននៃទម្រង់ទី១ និងទម្រង់ទី២ នៃសហឧក្រិដ្ឋកម្មរួម នៅចំពោះមុខ អ.វ.ត.ក ត្រូវបានគាំទ្របន្ថែមដោយអង្គបុរេជំនុំជម្រះ ដែលរកឃើញថា ទម្រង់ទាំងពីរនេះ គឺជាទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានគេទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលពាក់ព័ន្ធនៃសំណុំរឿង ០០២[៥៣]។ ដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូង

---

៥០ *សូមមើល* សាលក្រមសាលាដំបូងក្នុងរឿងក្តី *Simba,* កថាខណ្ឌ 415-419 និង សាលក្រមសាលាដំបូងក្នុងរឿងក្តី *Munyakazi,* កថាខណ្ឌ 500-501 (ដែលបានសន្និដ្ឋានថា នៅពេលដែលចេតនាឧក្រិដ្ឋនៃអំពើប្រល័យពូជសាសន៍ត្រូវបានបង្ហាញតាមការសន្និដ្ឋាននោះ ការសន្និដ្ឋានបែបនេះត្រូវតែជាសេចក្តីសន្និដ្ឋានតែមួយគត់ដែលមានសំអាងហេតុគ្រប់គ្រាន់ដោយផ្អែកលើភស្តុតាងដែលមានក្នុងពេលសវនាការ)។

៥១ សាលក្រម ឌុច កថាខណ្ឌ ៥១២។

៥២ សាលក្រម ឌុច កថាខណ្ឌ ៥១១ ដល់ ៥១៣។ នៅក្នុងសាលក្រម ឌុច នេះ ចៅក្រមមិនបានសម្រេចពីភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ទេ ដែលការអនុវត្តនៃទម្រង់នេះមិនអាចអនុវត្តបាននៅក្នុងសំណុំរឿង ឌុច ឡើយ។

៥៣ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៥៤ ដល់ ៧៣ (ដោយកត់សម្គាល់លើឯកសារតំណាងផ្លូវច្បាប់មួយចំនួន ក្នុងចំណោម

យល់ឃើញថា ភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទម្រង់ទី២ នៅចំពោះមុខ អ.វ.ត.ក បង្កើតឱ្យបានទៅជាច្បាប់នៅក្នុងយុត្តិសាស្ត្ររបស់ អ.វ.ត.ក។

## ៤.៤. ភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣

### *៤.៤.១. ភាពអាចទទួលយកបាននៃសំណើសុំរបស់សហព្រះរាជអាជ្ញា*

២៣. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ទ្រឹស្តីនៃរឿងក្តីរបស់សហព្រះរាជអាជ្ញា សំអាងយ៉ាងខ្លាំងទៅលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី១។ សហព្រះរាជអាជ្ញា លើកឡើងនៅក្នុងសំណើសុំរបស់ខ្លួនថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី១ ឆ្លុះបញ្ចាំងល្អបំផុតអំពីចរិតលក្ខណៈនៃការទទួលខុសត្រូវរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២[៥៤]។ សហព្រះរាជអាជ្ញា ស្នើសុំឱ្យបន្ថែមសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ តែក្នុងករណីដែលថា ទ្រឹស្តីចម្បងរបស់ខ្លួន មិនអាចអនុវត្តបានចំពោះអង្គហេតុមួយចំនួនប៉ុណ្ណោះ[៥៥]។ សហព្រះរាជអាជ្ញាលើកឡើងថា អាចមានលទ្ធភាពដែលថា អំពើឧក្រិដ្ឋមួយចំនួនដែលមានកម្រិតបំផុត ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ អាចមិនស្ថិតនៅក្នុងវិសាលភាពនៃផែនការឧក្រិដ្ឋកម្មរួម ដូចដែលបានយល់ឃើញកាលពីដំបូងៗនោះឡើយ[៥៦]។ ក្នុងករណីនេះ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងរក្សាឆន្ទានុសិទ្ធិ ដើម្បីផ្តន្ទាទោសចំពោះអំពើនេះ ដោយអនុលោមតាមសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ នៅក្នុងសាលក្រម ប្រសិនបើយល់ថាសមស្រប[៥៧]។

២៤. អង្គជំនុំជម្រះសាលាដំបូងក៏បានសម្រេចកាលពីមុនរួចមកហើយថា ដោយអនុលោមតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង ការកំណត់បទចោទជាថ្មីឡើងវិញអាចអនុវត្តទៅបាននៅចំពោះមុខ

ឯកសារផ្សេងៗទៀត ដូចជា ធម្មនុញ្ញទីក្រុងឡុងដ៍, ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ, រឿងក្តីអន្តរជាតិនានា និងសេចក្តីប្រកាសដែលជាឯកសារតំណាងផ្លូវច្បាប់ដទៃទៀត)។

[៥៤] សំណើសុំសហព្រះរាជអាជ្ញា កថាខណ្ឌ ២។

[៥៥] សំណើសុំសហព្រះរាជអាជ្ញា កថាខណ្ឌ ៣។

[៥៦] សំណើសុំសហព្រះរាជអាជ្ញា កថាខណ្ឌ ២។

[៥៧] សំណើសុំសហព្រះរាជអាជ្ញា កថាខណ្ឌ ៣។

អ.វ.ត.ក[៥៨]។ នៅក្នុងសាលក្រមសម្រេចលើរឿងក្តីរបស់ ឌុច អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ជនជាប់ចោទនៅក្នុងរឿងក្តីនេះបានទទួលដំណឹងថា បញ្ហាសហឧក្រិដ្ឋកម្មរួម គឺស្ថិតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងថា អង្គជំនុំជម្រះសាលាដំបូងមានបំណងសម្រេចអំពីបញ្ហានេះនៅក្នុងសាលក្រម។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ការអនុវត្តទម្រង់នៃការទទួលខុសត្រូវនេះមិនរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទនោះទេ[៥៩]។

២៥. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ខ្លួនអាចកែប្រែបទចោទជាថ្មីឡើងវិញ ដែលបានកំណត់ក្នុងដីកាដំណោះស្រាយដែលត្រូវបានកែប្រែ នៅពេលណាមួយក៏បាន ដើម្បីឱ្យស្របតាមទម្រង់ដទៃទៀតនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលអាចអនុវត្តបាន និងរួមទាំងនៅក្នុងសាលក្រមផងដែរ។ នេះគឺអាស្រ័យទៅលើលក្ខខណ្ឌតម្រូវលើសលុបនៃការជំនុំជម្រះក្តីដោយយុត្តិធម៌[៦០]។ ខុសពីសំណុំរឿង ០០១ ទោះបីជាសហព្រះរាជអាជ្ញាមិនបានជូនដំណឹងដល់ភាគីនានា និងចៅក្រមនៅក្នុងសវនាការបឋមថា សហព្រះរាជអាជ្ញាអាចនឹងស្នើសុំឱ្យអង្គជំនុំជម្រះ ពិចារណាទៅលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ នៅក្នុងរឿងក្តីនេះក៏ដោយ ក៏សំណើសុំបានលើកឡើងពីបញ្ហានេះនៅមុនការចាប់ផ្តើមការជំនុំជម្រះលើអង្គសេចក្តី[៦១]។ អាស្រ័យហេតុនេះ មិនមានភាពអយុត្តិធម៌ចំពោះជនជាប់ចោទ នៅក្នុងការពិចារណាទៅលើសំណើសុំរបស់សហព្រះរាជអាជ្ញានាពេលនេះទេ។

---

[៥៨] សាលក្រមសម្រេចលើរឿងក្តីរបស់ ឌុច កថាខណ្ឌ ៤៩៦។

[៥៩] សាលក្រមសម្រេចលើរឿងក្តីរបស់ ឌុច កថាខណ្ឌ ៥០៣។

[៦០] នៅក្នុងបរិបទជាក់លាក់របស់ អ.វ.ត.ក ចំណុចនេះតម្រូវឱ្យអង្គជំនុំជម្រះស្ថិតនៅក្នុងព្រំដែននៃអង្គហេតុ ដែលមាននៅក្នុងដីកាដំណោះស្រាយ (សូមមើល វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង៖ សាលក្រមត្រូវតែសម្រេចត្រឹមតែអង្គហេតុទាំងឡាយណាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះតែប៉ុណ្ណោះ។ អង្គជំនុំជម្រះ អាចផ្លាស់ប្តូរការកំណត់បទចោទដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែ មិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ)។

[៦១] សាលក្រមសម្រេចលើរឿងក្តីរបស់ ឌុច កថាខណ្ឌ ៤៨៩ លេខយោងជើងទំព័រ ៨៦២។ សូមមើលផងដែរ ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យមានការអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនៅក្នុងរឿងក្តីនេះ ឯកសារ E73/2 ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៩ កថាខណ្ឌ ៧ ដល់ ១៣ (ការជជែកតវ៉ាអំពីភាពអាចទទួលយកបាននៃសំណើសុំដោយសារតែអង្គបុរេជំនុំជម្រះបានដកសហឧក្រិដ្ឋកម្មរួមនេះចេញពីដីកាដំណោះស្រាយដែលបានកែប្រែ និងដោយសារតែសហព្រះរាជអាជ្ញាមិនបានយកបញ្ហាសហឧក្រិដ្ឋកម្មរួមនេះ មកដេញដោលឱ្យបានល្អិតល្អន់គ្រប់គ្រាន់នោះឡើយ)។

អង្គជំនុំជម្រះយល់ឃើញថា សំណើសុំរបស់សហព្រះរាជអាជ្ញាឱ្យកែប្រែបទចោទជាថ្មីឡើងវិញ មិនរំលោភសិទ្ធិរបស់ជនជាប់ចោទដែលត្រូវទទួលបានការជូនដំណឹងអំពីបទចោទប្រឆាំងនឹងរូបគាត់ ឬមិនរំលោភលើគោលការណ៍ទទួលបានការជំនុំជម្រះដោយយុត្តិធម៌ណាមួយនោះទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូង បដិសេធសំណើក្រោយរបស់ អៀង សារី សុំឱ្យសម្រេចលើបញ្ហានេះ ដោយគ្រាន់តែផ្អែកលើមូលដ្ឋាននៃភាពអាចទទួលយកបានតែប៉ុណ្ណោះ[៦២]។

### *៤.៤.២. អង្គសេចក្តីនៃសំណើសុំរបស់សហព្រះរាជអាជ្ញា*

២៦. ជាបឋម អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ត្រូវបានយកមកសួរដេញដោលយ៉ាងល្អិតល្អន់នៅចំពោះមុខ អ.វ.ត.ក។ បញ្ហានេះក៏បានឆ្លងកាត់ការពិនិត្យពិច័យជាថ្មី នៅចំពោះមុខអង្គបុរេជំនុំជម្រះ នៅក្នុងសំណុំរឿង ០០២។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងមិនមែនជាតុលាការជាន់ខ្ពស់ ឬជាស្ថាប័នដែលត្រូវពិនិត្យសេចក្តីសម្រេចនានារបស់អង្គបុរេជំនុំជម្រះឡើងវិញក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងនាពេលនេះបានប្រឈមមុខជាមួយនឹងសំណើសុំមួយ ដែលមានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងសំណើសុំពីមុននៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ដើម្បីជាការសន្សំសំចៃផ្នែកធនធានតុលាការ អង្គជំនុំជម្រះសាលាដំបូងនឹងមិនចេញសេចក្តីសម្រេចដែលវែងនោះទេ ក្នុងកាលៈទេសៈទាំងឡាយដែលអង្គជំនុំជម្រះសាលាដំបូងមិនអាចរកឃើញមូលហេតុរឹងមាំ ដើម្បីងាកចេញពីការវិភាគរបស់អង្គបុរេជំនុំជម្រះ និងក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយនឹងលទ្ធផលរបស់អង្គបុរេជំនុំជម្រះ។

#### <u>៤.៤.២.១ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ</u>

២៧. សាលដីការបស់អង្គបុរេជំនុំជម្រះសម្រេចអំពីសហឧក្រិដ្ឋកម្មរួម បានពិនិត្យឡើងវិញយ៉ាងល្អិតល្អន់ទៅលើលិខិតុបករណ៍ច្បាប់មុនឆ្នាំ ១៩៧៥ រួមទាំងធម្មនុញ្ញរបស់តុលាការ Nuremberg និងច្បាប់

[៦២] សូមមើល សំណើរបស់ អៀង សារី សុំឱ្យមានសេចក្តីសម្រេចជាបន្ទាន់ទាក់ទងនឹងបញ្ហាថា តើសហព្រះរាជអាជ្ញា អាចស្នើសុំឱ្យផ្លាស់ប្តូរការកំណត់បទចោទ នៅដំណាក់កាលនេះនៃនីតិវិធី ដែរឬអត់, ឯកសារ E103 ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១។

លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យប្រទេសអាល្លឺម៉ង់ (Control Council Law)។ អង្គបុរេជំនុំជម្រះបានយល់ស្របជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសាលក្រមសម្រេចលើរឿងក្ដីរបស់ ឌុច ដែលថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងសហឧក្រិដ្ឋកម្មរួមទម្រង់ទី២ ត្រូវបានទទួលស្គាល់ថា ជាទម្រង់នៃការទទួលខុសត្រូវ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងពេលពាក់ព័ន្ធនឹងសំណុំរឿង ០០២[៦៣]។ ប៉ុន្តែ អង្គបុរេជំនុំជម្រះបានសម្រេចថា លិខិតុបករណ៍អន្តរជាតិទាំងនេះមិនបានទទួលស្គាល់សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ឲ្យបានច្បាស់លាស់នោះទេ[៦៤]។ អង្គបុរេជំនុំជម្រះក៏បានពិនិត្យមើលករណីមួយចំនួន ក្រោយសង្គ្រាមលោកលើកទីពីរ ដែលបានលើកឡើងនៅក្នុងសាលដីកាសម្រេចលើរឿងក្ដីរបស់ *Tadić* រួមទាំងរឿងក្ដីនៅកោះ *Borkum* និងរឿងក្ដីសម្លាប់ដោយហ្វូងមនុស្សនៅទីក្រុង *Essen* ដើម្បីពិចារណា ថាតើច្បាប់ទំនៀមទម្លាប់អន្តរជាតិ បានរាប់បញ្ចូលសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ថាជាទម្រង់មួយនៃការទទួលខុសត្រូវដែរឬយ៉ាងណា នៅក្នុងពេលវេលាដែលជាប់ពាក់ព័ន្ធនោះ[៦៥]។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា ករណីទាំងអស់ដែលបានសម្រេច ដោយអនុលោមតាមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ មិនបានគាំទ្រដល់ការយល់ឃើញណាមួយដែលថា ការផ្ដន្ទាទោសទាំងអស់នេះត្រូវបានសំអាងទៅលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ នោះទេ[៦៦]។ អង្គបុរេជំនុំជម្រះបានយល់ឃើញបន្ថែមទៀតថា ច្បាប់ជាតិមួយចំនួនដែលបានយកមកជាសំអាង ដើម្បីគាំទ្រដល់ការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ក៏មិនបានផ្ដល់ភស្តុតាងឲ្យបានគ្រប់គ្រាន់ពីការអនុវត្តដែលស៊ីសង្វាក់គ្នាកម្រិតរដ្ឋ ឬ នៃសច្ចធារណ៍ធម្មានុរូប (*opinio juris*) ចំពោះពេលវេលាដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ នោះដែរ[៦៧]។

---

៦៣ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម។ អង្គបុរេជំនុំជម្រះ ឯកសារលេខ D97/15/9 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៦៩ និងកថាខណ្ឌ ៧២ (“សាលដីកា អ.ប.ជ សម្រេចអំពីសហឧក្រិដ្ឋកម្មរួម”)។

៦៤ “សាលដីកា អ.ប.ជ សម្រេចអំពីសហឧក្រិដ្ឋកម្មរួម” កថាខណ្ឌ ៧៨។

៦៥ “សាលដីកា អ.ប.ជ សម្រេចអំពីសហឧក្រិដ្ឋកម្មរួម” កថាខណ្ឌ ៧៩ ដល់ ៨២។

៦៦ “សាលដីកា អ.ប.ជ សម្រេចអំពីសហឧក្រិដ្ឋកម្មរួម” កថាខណ្ឌ ៨០។

៦៧ “សាលដីកា អ.ប.ជ សម្រេចអំពីសហឧក្រិដ្ឋកម្មរួម” កថាខណ្ឌ ៨២។

២៨. ទីបំផុត អង្គបុរេជំនុំជម្រះបានពិចារណា ថាតើសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ គួរត្រូវបានបញ្ជាក់ថាជាទម្រង់មួយនៃការទទួលខុសត្រូវ ដែលជា "គោលការណ៍ទូទៅនៃច្បាប់ដែលបានទទួលស្គាល់ដោយអារ្យប្រទេសដែរ ឬយ៉ាងណា"[៦៨]។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់សេចក្តីសន្និដ្ឋាននៅក្នុងសាលដីកាសម្រេចលើរឿងក្តីរបស់ *Tadić* ដែលថា ការទទួលខុសត្រូវចំពោះគោលបំណងរួមមិនត្រូវបានទទួលយកនៅក្នុងប្រព័ន្ធច្បាប់ជាតិភាគច្រើននោះទេ[៦៩]។ ប៉ុន្តែ ទីបំផុត អង្គបុរេជំនុំជម្រះមិនបានសម្រេច ថាតើសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ បាននាំឱ្យក្លាយទៅជាគោលការណ៍ទូទៅនៃច្បាប់ដែរ ឬយ៉ាងណានោះទេ ដោយយោងទៅលើមូលដ្ឋាននានាដែលថា គោលការណ៍បែបនេះមិនអាចជាការប្រមើលដឹងជាមុនឱ្យបានគ្រប់គ្រាន់ និងមិនអាចអនុវត្តបានចំពោះជនជាប់ចោទនៅក្នុងសំណុំរឿង ០០២ នោះទេ ដោយសារថា មិនមានមូលដ្ឋានសម្រាប់ការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ នៅក្នុងច្បាប់របស់កម្ពុជា[៧០]។

២៩. ដោយយោងទៅលើសំអាងហេតុដូចមានបញ្ជាក់ខាងក្រោមនេះ អង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយនឹងការវិភាគរបស់អង្គបុរេជំនុំជម្រះ ទៅលើករណីទាំងឡាយនៅក្រោយសង្គ្រាមលោកលើកទីពីរ ដូចដែលបានលើកឡើងខាងលើ។ លើសពីនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងបាន

---

៦៨ "សាលដីកា អ.ប.ជ សម្រេចអំពីសហឧក្រិដ្ឋកម្មរួម" កថាខណ្ឌ ៨៤។ "គោលការណ៍ទូទៅនៃច្បាប់ដែលបានទទួលស្គាល់ដោយអារ្យប្រទេស" គឺជាប្រភពនៃច្បាប់ ដែលសុខពីច្បាប់ទំនៀមទម្លាប់ និងច្បាប់អនុសញ្ញា "conventional law" (សូមមើល លក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិ មាត្រា ៣៨(១)(គ))។ វាមិនច្បាស់លាស់នោះទេ ទាំងនៅក្នុងច្បាប់យុត្តិសាស្ត្រ និងទាំងនៅក្នុងស្នាដៃស្រាវជ្រាវ ដែលថាតើគោលការណ៍នេះអាចបញ្ជាក់ដោយឯករាជ្យថាជាប្រភពនៃគោលការណ៍ច្បាប់អន្តរជាតិ សម្រាប់ការអនុវត្តជាទូទៅដែរឬយ៉ាងណានោះ ឬផ្ទុយទៅវិញថាតើវាគ្រាន់តែជាអំណះអំណាងបន្ថែមដែលថា គោលការណ៍នេះត្រូវបានទទួលស្គាល់ថាជានិយាមនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ (a norm of customary international law) ដែរឬយ៉ាងណានោះ។ ជាឧទាហរណ៍ សូមមើល សៀវភៅដែលនិពន្ធដោយ Malcolm Shaw ដែលមានចំណងជើងថា ច្បាប់អន្តរជាតិ (Cambridge ២០០៣) ទំព័រ ៩៣ ដល់ ៩៩ ["មានយោបល់ផ្សេងៗគ្នាថាតើគោលការណ៍ទូទៅនៃច្បាប់មានបំណងយកមកសំអាងត្រឹមកម្រិតណាដែរនោះ ..... អ្នកនិពន្ធភាគច្រើនបានត្រៀមខ្លួនរួចជាស្រេចដើម្បីទទួលស្គាល់ថា គោលការណ៍ទូទៅបង្កបានជាប្រភពមួយដាច់ដោយឡែកនៃច្បាប់ ប៉ុន្តែ មានវិសាលភាពតិចតួចបំផុត ហើយចំណុចត្រង់នេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីសម្រេចនានារបស់តុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍ (Permanent Court of International Justice)"]។

៦៩ សូមមើល សាលដីការបស់ អ.ប.ជ សម្រេចអំពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៥ ដែលធ្វើការសំអាងទៅលើសាលដីកាសម្រេចលើរឿងក្តីរបស់ *Tadić* កថាខណ្ឌ ២២៥ ដល់ ២២៦។

៧០ សាលដីការបស់ អ.ប.ជ សម្រេចអំពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៧។

ធ្វើការវិភាគដោយខ្លួនឯងផ្ទាល់ទៅលើវិសាលភាពសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ដែលត្រូវបានទទួលស្គាល់ដោយប្រព័ន្ធច្បាប់ជាតិផ្សេងៗ។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ មិនអាចយកមកពិចារណាថាជាគោលការណ៍ទូទៅនៃច្បាប់បានទេ។

### <u>៤.៤.២.២. រឿងក្តីនៅក្រោយសម័យសង្គ្រាមលោកលើកទី ២ ដែលត្រូវបានយោងនៅក្នុងសាលក្រមលើបណ្តឹងឧទ្ធរណ៍នៅក្នុងរឿងក្តី *Tadić*</u>

#### ៤.៤.២.២.១. រឿងក្តីនៅកោះ ***Borkum*** និងរឿងក្តីសម្លាប់ដោយហ្វូងមនុស្សនៅទីក្រុង ***Essen***

៣០. នៅក្នុងរឿងក្តីនៅកោះ *Borkum* លិខិតុបករណ៍ច្បាប់ត្រូវបានយកមកធ្វើការចោទប្រកាន់ជនជាតិអាល្លឺម៉ង់មួយចំនួនថាបានជំរុញ បានជួយ បានជ្រោមជ្រែង និងបានចូលរួមដោយខុសច្បាប់ នៅក្នុងការវាយប្រហារ និងការសម្លាប់អាកាសយានិកជនជាតិអាមេរិកចំនួន៧នាក់[៧១]។ ជនជាតិអាមេរិកបានធ្លាក់យន្តហោះនៅកោះ Borkum ហើយមេបញ្ជាការយោធាអាល្លឺម៉ង់មួយរូបបានបញ្ជាឲ្យអង្គភាពឆ្មាំមួយក្រុមបណ្តើរជនជាតិអាមេរិកទាំងនោះកាត់ទីក្រុង ដោយមិនបានផ្តល់ការការពារទប់ស្កាត់នឹងការវាយប្រហារពីសំណាក់ជនស៊ីវិលនោះទេ។ ជនជាតិអាមរិកទាំងនោះត្រូវបានសាធារណជនមួយចំនួនវាយតប់ ហើយមានហេតុការណ៍មួយបានកើតឡើងដែលថា ជនជាតិអាមេរិកម្នាក់ត្រូវបានបាញ់សម្លាប់ដោយទាហានអាល្លឺម៉ង់ម្នាក់ ដែលចប់វេនប្រចាំការ។ នៅទីបំផុត ជនជាតិអាមេរិកទាំងប្រាំពីរនាក់ត្រូវបានគេសម្លាប់[៧២]។ ជនជាប់ចោទចំនួនដប់ប្រាំនាក់ ត្រូវបានកាត់ទោសចំពោះការស្លាប់នេះ រួមទាំងជនស៊ីវិលពីរនាក់ នាយទាហានប្រាំនាក់ និងសមាជិក

---

[៧១] សូមមើល រឿងក្តីរវាង សហរដ្ឋអាមេរិក តទល់នឹង *Haesiker* សំណុំរឿងលេខ 12-489-1 ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៤៧ សាលក្រមពិនិត្យឡើងវិញ (ដោយសំអាងទៅលើអង្គហេតុដដែល ដូចមាននៅក្នុងរឿងក្តីរវាង សហរដ្ឋអាមេរិក តទល់នឹង *Goebell* ព្រមទាំងអ្នកផ្សេងទៀត ពីថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ដល់ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៤៦ ("រឿងក្តីនៅកោះ *Borkum*")។

[៧២] រឿងក្តីនៅកោះ *Borkum* កថាខណ្ឌ ១៩១។

មួយចំនួននៃក្រុមឆ្នាំនេះ[៧៣]។ ជនជាប់ចោទចំនួនដប់បួននាក់ ក្នុងចំណោមជនជាប់ចោទទាំងដប់ប្រាំនាក់ ត្រូវបានផ្តន្ទាទោស និងបានទទួលការកាត់ទោសឱ្យជាប់ពន្ធនាគារចន្លោះពី ពីរឆ្នាំរហូតដល់ប្រហារជីវិត[៧៤]។ ប៉ុន្តែ មូលដ្ឋានសម្រាប់ការផ្តន្ទាទោសទាំងនេះ មិនអាចបញ្ជាក់ឱ្យបានប្រាកដប្រជាទេ ដោយសារការមិនបានចេញសាលក្រមដែលមានសំអាងហេតុច្បាស់លាស់។ ភាពមិនច្បាស់លាស់ចេញពីសាលក្រមនោះដែរ គឺកម្រិតនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ ដែលត្រូវបានរកឃើញចំពោះអំពើដែលជនជាប់ចោទនោះមិនបានប្រព្រឹត្តដោយផ្ទាល់។ បើទោះបីជាមូលដ្ឋានសម្រាប់ការផ្តន្ទាទោសនៅក្នុងរឿងក្តីនេះ អាចជាសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វាអាចជាការផ្តន្ទាទោសតាមទម្រង់ដទៃទៀតផងដែរ។

៣១. ស្រដៀងគ្នានេះដែរ កំណត់ត្រានៃសាលក្រមនៅក្នុងរឿងក្តីសម្លាប់ដោយហ្វូងមនុស្សនៅទីក្រុង *Essen* មានតែសម្រង់សាលក្រមដែលផ្តល់ដោយគណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិតែប៉ុណ្ណោះ[៧៥]។ មូលដ្ឋានច្បាប់សម្រាប់ការផ្តន្ទាទោសរបស់ខ្លួននេះក៏មិនច្បាស់លាស់ដែរ។ តាមពិតទៅ សម្រង់នៃសេចក្តីសម្រេចនេះបានយោងទៅលើការជំរុញ ការញុះញង់ ការបញ្ជា និងការផ្តល់ការគាំទ្រដល់សេចក្តីសន្និដ្ឋានដែលថា ការផ្តន្ទាទោសទាំងនេះអាចត្រូវបានសំអាងទៅលើទម្រង់ដទៃទៀតនៃការទទួលខុសត្រូវ[៧៦]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អំណះអំណាងដែលបានបង្ហាញនៅក្នុងសាលដីកាសម្រេចលើរឿងក្តី *Tadić* ដែលថា ការផ្តន្ទាទោសនេះត្រូវបានផ្អែកលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣នោះ មិនមែនជាការសំអាងដែលអាចមានតែមួយគត់នោះទេ យោងតាមកំណត់ត្រាដែលនៅសល់។

---

៧៣ រឿងក្តីនៅកោះ *Borkum* កថាខណ្ឌ ១៩១។

៧៤ រឿងក្តីនៅកោះ *Borkum* កថាខណ្ឌ ១៩១។

៧៥ សវនាការជំនុំជម្រះលើជនជាប់ចោទឈ្មោះ *Erich Heyer* និងជនជាប់ចោទប្រាំមួយនាក់ទៀត ដែលជំនុំជម្រះទៅលើឧក្រិដ្ឋជនសង្គ្រាម ដោយតុលាការយោធាអង់គ្លេស នៅក្នុងទីក្រុង Essen ពីថ្ងៃទី ១៨ ដល់ ១៩ និងពីថ្ងៃទី ២១ ដល់ ២២ ខែធ្នូ ឆ្នាំ ១៩៤៥ UNWCC វ៉ុលលេខ ១ (១៩៤៩) ("រឿងក្តីសម្លាប់ដោយហ្វូងមនុស្សនៅទីក្រុង *Essen*")។

៧៦ រឿងក្តីសម្លាប់ដោយហ្វូងមនុស្សនៅទីក្រុង *Essen* ទំព័រ ៨៩ ដល់ ៩០។

## ៤.៤.២.៣. រឿងក្តីដទៃទៀតពីសម័យសង្គ្រាមលោកលើកទីពីរ

៣២. អង្គជំនុំជម្រះសាលាដំបូងបានពិចារណាបន្ថែមទៀត ទៅលើសេចក្តីសម្រេចពាក់ព័ន្ធដទៃទៀតដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចនាពេលថ្មីៗ របស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ ដែលបានចេញ បន្ទាប់ពីសាលដីការបស់អង្គបុរេជំនុំជម្រះ សម្រេចអំពីសហឧក្រិដ្ឋកម្មរួម[៧៧]។ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យមើលឡើងវិញ ទៅលើរឿងក្តីបន្ថែមទៀតពីសម័យសង្គ្រាមលោកលើកទី២ ប៉ុន្តែ បានពិចារណាឃើញថា រឿងក្តីទាំងនេះក៏មិនបានគាំទ្រដល់សេចក្តីសន្និដ្ឋាន ចំពោះអត្ថិភាពនៃសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ នៅក្នុងច្បាប់អន្តរជាតិជាទូទៅ រវាងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ។

៣៣. ទោះបីជាសេចក្តីសម្រេចចាត់របៀបរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ យល់ឃើញថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ អាចយកមកអនុវត្តបានក៏ដោយ ក៏វាខុសគ្នាពីសាលដីការបស់អង្គបុរេជំនុំជម្រះ សម្រេចអំពីសហឧក្រិដ្ឋកម្មរួមដែរ បើយោងទៅលើភាពពាក់ព័ន្ធនៃយុត្តិសាស្ត្ររបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ ដែលបានបង្កើតនៅដើមទសវត្សរ៍ឆ្នាំ ១៩៩០[៧៨]។ ប៉ុន្តែ សេចក្តីសម្រេចចាត់របៀបរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ ក៏បានសំអាងទៅលើរឿងក្តីពីសម័យក្រោយសង្គ្រាមលោកលើកទីពីរបន្ថែមទៀត ដែលសេចក្តីសម្រេចនេះអះអាងពីការគាំទ្រដល់អត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ដែលស្ថិតនៅក្នុងច្បាប់អន្តរជាតិទូទៅ[៧៩]។

៣៤. រឿងក្តីចំនួនពីរក្នុងចំណោមរឿងក្តីទាំងនេះគឺ រឿងក្តីរវាង សហរដ្ឋអាមេរិក តទល់នឹង *Ulrich* និង *Merkle* និងរឿងក្តីរវាងសហរដ្ឋអាមេរិក តទល់នឹង *Wuelfert* មានប្រភពពីតុលាការយោធានៅទីក្រុង Dachau[៨០]។ រឿងក្តីទាំងនេះពាក់ព័ន្ធនឹងអ្នកជំនួញឯកជន ដែលជាម្ចាស់កម្មសិទ្ធិរោងចក្រ

---

[៧៧] សំណុំរឿងលេខ STL-11-01/1 សេចក្តីសម្រេចចាត់របៀបអំពីច្បាប់ដែលអាចយកមកអនុវត្តបាន៖ អំពើភេរវកម្ម ការសមគំនិត អំពើមនុស្សឃាត ការប្រព្រឹត្តបទឧក្រិដ្ឋ បទចោទគ្រួត តុលាការពិសេសសម្រាប់ប្រទេសលីបង់ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ ("សេចក្តីសម្រេចចាត់របៀបរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់")។

[៧៨] សេចក្តីសម្រេចចាត់របៀបរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ កថាខណ្ឌ ២៣៩ លេខយោងជើងទំព័រ ៣៦០។

[៧៩] សេចក្តីសម្រេចចាត់របៀបរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ កថាខណ្ឌ ២៣៩ លេខយោងជើងទំព័រ ៣៦០។

[៨០] រឿងក្តីរវាង សហរដ្ឋអាមេរិក តទល់នឹង *Ulrich* និង *Merkle* សំណុំរឿងលេខ 000-50-2-17, Deputy Judge Advocate's Office ប្រភេទឧក្រិដ្ឋកម្មសង្គ្រាម ៧៧០៨-ការបង្គាប់ ការពិនិត្យឡើងវិញ និងអនុសាសន៍របស់សហគមន៍អឺរ៉ុប ចុះថ្ងៃទី ១២

នៅជិតជំរំប្រមូលផ្តុំនៅទីក្រុង Dachau និងបានប្រើអ្នកទោសឱ្យធ្វើការនៅក្នុងរោងចក្ររបស់ខ្លួន ចំពោះពលកម្មបែបទាសករ។ ពួកគេត្រូវបានសម្រេចឱ្យទទួលខុសត្រូវចំពោះការប្រព្រឹត្តដោយអមនុស្សធម៌មកលើអ្នកទោសនៅជំរំ Dachau និងនៅឯរោងចក្រទាំងនោះ រួមមាន ការសម្លាប់ ការវាយដំ ការធ្វើទារុណកម្ម និងការបង្អត់អាហារ។ ជាថ្មីម្តងទៀត សេចក្តីសម្រេចចាត់របៀបរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់នេះ សំអាងទៅលើការពិនិត្យមើលសាលក្រមទាំងនោះឡើងវិញដែលមិនផ្តល់មូលដ្ឋានគតិយុត្តិ ចំពោះការផ្តន្ទាទោសដែលបានបញ្ជាក់រួចហើយនោះទេ។ សាលដីកាពិនិត្យឡើងវិញនៅក្នុងរឿងក្តីរវាង សហរដ្ឋអាមេរិក តទល់នឹង *Ulrich* គ្រាន់តែសន្និដ្ឋានថា "ជនជាប់ចោទទាំងពីរនាក់ត្រូវបានរកឃើញថា បានចូលរួមនៅក្នុងការសម្លាប់ទ្រង់ទ្រាយធំ ហើយតុលាការបានចាប់ខ្លួន ដោយសារតែភស្តុតាងដែលបានសំអាង ... នៅក្នុងការសន្និដ្ឋាន .... ថា ពួកគេមិនគ្រាន់តែបានចូលរួមនៅក្នុងកម្រិតធ្ងន់ធ្ងរប៉ុណ្ណោះទេ ប៉ុន្តែ ចរិត និងវិសាលភាពនៃការចូលរួមរបស់ពួកគេបែបនេះ គឺនាំឱ្យមានការផ្តន្ទាទោសដូចដែលបានកំណត់ឡើង[៨១]។ រឿងក្តីទាំងនេះហាក់គាំទ្រចំពោះសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ ឬ សហឧក្រិដ្ឋកម្មរួមទម្រង់ទី២ ដោយសារជនជាប់ចោទមានតួនាទីនៅក្នុងជំរំឃុំឃាំង និងបានចូលរួមដោយផ្ទាល់ក្នុងការប្រព្រឹត្តដោយអមនុស្សធម៌មកលើអ្នកទោស។ ឧក្រិដ្ឋកម្មទាំងនេះមិនគាំទ្រចំពោះពិរុទ្ធភាពដែលផ្អែកលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ នោះទេ ពោលគឺ នេះគឺជាការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលស្ថិតនៅក្រៅវិសាលភាពនៃផែនការរួម តែទោះជាយ៉ាងណាក៏ដោយ គឺចំពោះផលវិបាកជាធម្មតា និងដែលអាចប្រមើលដឹងជាមុនបានពីផែនការនោះ។

---

ខែ មិថុនា ឆ្នាំ ១៩៤៧ ការពិនិត្យឡើងវិញរបស់តុលាការឧក្រិដ្ឋកម្មសង្គ្រាមរបស់សហរដ្ឋអាមេរិកនៅអឺរ៉ុប ចន្លោះពីឆ្នាំ ១៩៤៥ ដល់ ១៩៤៨ ដែលរកបាននៅលើគេហទំព័រ http://www.jewishvirtuallibrary.org/jsource/Holocaust/dachautrial/d19.pdf ("រឿងក្តីរបស់ *Ulrich* និង *Merkle*") និងរឿងក្តីរវាង សហរដ្ឋអាមេរិក តទល់នឹង *Hans Wuelfert* និងអ្នកផ្សេងទៀត សំណុំរឿងលេខ 000-50-2-72, Deputy Judge Advocate's Office ប្រភេទឧក្រិដ្ឋកម្មសង្គ្រាម ៧៧០៨-ការបង្ហាប់ ការពិនិត្យឡើងវិញ និងអនុសាសន៍របស់សហគមន៍អឺរ៉ុប ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៤៧ ការពិនិត្យឡើងវិញរបស់តុលាការឧក្រិដ្ឋកម្មសង្គ្រាមរបស់សហរដ្ឋអាមេរិកនៅអឺរ៉ុប ចន្លោះពីឆ្នាំ ១៩៤៥ ដល់ ១៩៤៨ ដែលរកបាននៅលើគេហទំព័រ http://dev.jewishvirtuallibrary.org/items/7110.html ("រឿងក្តីរបស់ *Wuelfert*")។

[៨១] រឿងក្តីរបស់ *Ulrich* និង *Merkle* ផ្នែកទី ៥ ("គំនិតយោបល់")។

៣៥. អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមិនយល់ឃើញថា លិខិតុបករណ៍ច្បាប់បន្ថែមទាំងនេះ គាំទ្រដល់សេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ បានលេចឡើងជាគោលការណ៍មួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅអំឡុងពេលពាក់ព័ន្ធនឹងសំណុំរឿង ០០២ នោះទេ។

## ៤.៤.២.៤. សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ គឺជា "គោលការណ៍ទូទៅនៃច្បាប់"

៣៦. ចុងបញ្ចប់ សហព្រះរាជអាជ្ញាបានយោងទៅលើក្រមព្រហ្មទណ្ឌជាតិមួយចំនួន ដើម្បីបង្ហាញថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ បង្កបានជា "គោលការណ៍ទូទៅនៃច្បាប់ដែលបានទទួលស្គាល់ដោយអារ្យប្រទេស" នៅរវាងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[៨២]។ ដោយសារអង្គបុរេជំនុំជម្រះមិនបានសម្រេចឱ្យបានច្បាស់លាស់ទៅលើបញ្ហា ថាតើសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ បង្កបានជា "គោលការណ៍ទូទៅនៃច្បាប់" ឬយ៉ាងណានោះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាបន្ថែមទៀតទៅលើទឡ្ហីករណ៍ទាំងនេះ។

៣៧. នៅក្នុងសាលដីកាសម្រេចលើរឿងក្តីរបស់ *Tadić* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY យល់ឃើញថា "ការសំអាងទៅលើច្បាប់ជាតិ និងករណីយុត្តិសាស្ត្រ គ្រាន់តែបង្ហាញថា សញ្ញាណនៃគោលបំណងរួមដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ មានការគាំទ្រនៅក្នុងប្រព័ន្ធច្បាប់ជាតិជាច្រើន"[៨៣]។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នោះបានសង្កត់ធ្ងន់ថា នៅក្រោមទ្រឹស្តីនៃគោលការណ៍ទូទៅនៃច្បាប់ ដែលបានទទួលស្គាល់ដោយបណ្តាប្រទេសនៅក្នុងពិភពលោកនេះ "ច្បាប់ជាតិ និងករណីយុត្តិសាស្ត្រ មិនអាចយកមកជាសំអាងថាជាប្រភពនៃគោលការណ៍អន្តរជាតិ ឬជាប្រភពនៃវិធានច្បាប់បានទេ៖ ដើម្បីឱ្យការសំអាងនេះអាចទទួលយកបាន នោះវាជាការចាំបាច់ដែលត្រូវបង្ហាញថា ប្រទេសភាគច្រើនសម្រេចតាមសញ្ញាណដូចគ្នានៃគោលបំណងរួម"[៨៤]។ ការស្រាវជ្រាវផ្ទាល់របស់អង្គជំនុំជម្រះសាលាដំបូងទៅលើប្រព័ន្ធច្បាប់

---

[៨២] សំណើសុំ កថាខណ្ឌ ២៩ (ចង្អុលបង្ហាញពីក្រមព្រហ្មទណ្ឌប្រទេសហ្វីលីពីន បារាំង និងអ៊ីតាលី)។

[៨៣] សាលដីកាសម្រេចលើរឿងក្តីរបស់ *Tadić* កថាខណ្ឌ ២២៥។

[៨៤] សាលដីកាសម្រេចលើរឿងក្តីរបស់ *Tadić* កថាខណ្ឌ ២២៥។

ជាតិមួយចំនួន រួមមាន ចក្រភពអង់គ្លេស[៨៥] សហរដ្ឋអាមេរិក[៨៦] ប្រទេសអាល្លឺម៉ង់[៨៧] សហភាពសូវៀត[៨៨] ប្រទេសហូឡង់[៨៩] ប្រទេសបារាំង[៩០] និងប្រទេសកម្ពុជា[៩១] ក៏បានបង្ហាញឱ្យឃើញនូវភាព

---

[៨៥] ទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ដែលតុលាការអង់គ្លេសយកមកអនុវត្តនៅឆ្នាំ ១៩៧៥ បានកំណត់ការទទួលខុសត្រូវតែចំពោះឧក្រិដ្ឋកម្ម ដែលត្រូវបាន "អនុញ្ញាត" ដោយសហឧក្រិដ្ឋកម្មរួមតែប៉ុណ្ណោះ។ ទម្រង់នៃការទទួលខុសត្រូវនេះគឺមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងសហឧក្រិដ្ឋកម្មរួមទម្រង់ទី ១ ជាជាងសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ (ជាឧទាហរណ៍សូមមើល *Anderson* និង *Morris* (1966) 2 QB 110។ សូមមើលផងដែរ A. Ashworth គោលការណ៍នៃច្បាប់ព្រហ្មទណ្ឌ "Oxford ឆ្នាំ ១៩៩៩" ទំព័រ ៤៤៨)។

[៨៦] នៅក្នុងសហរដ្ឋអាមេរិក ប្រភេទនៃការទទួលខុសត្រូវទៅលើគោលបំណងរួមស្ថិតនៅក្រោមឈ្មោះថា ការសមគំនិត (ជាឧទាហរណ៍សូមមើល *Pinkerton* ទល់នឹង សហរដ្ឋអាមេរិក 328 U.S. 640 (1946))។ ប៉ុន្តែ បទសមគំនិត គឺជាបទល្មើសមួយច្បាស់លាស់ ដែលបានសម្រេចបន្ទាប់ពីការព្រមព្រៀងគ្នាប្រព្រឹត្តបទល្មើស និងមិនមែនជាទម្រង់នៃការទទួលខុសត្រូវនោះទេ។

[៨៧] ទម្រង់មួយនៃចេតនានៅក្នុងក្រមព្រហ្មទណ្ឌអាល្លឺម៉ង់ ត្រូវបានគេស្គាល់ថាជាចេតនាដោយប្រយោល (*dolus eventualis*) (សូមមើល P. Cramer និង G. Heine នៅក្នុងរឿងក្តី A. Schoenke, H. Schroeder និងអ្នកផ្សេងទៀត។ Strafgesetzbuch Kommentar (បោះពុម្ពលើកទី ២៧ ទីក្រុង Munich៖ C.H. Beck, ឆ្នាំ ២០០៦ ទំព័រ ២៧៧)។ ប៉ុន្តែ តុលាការជាន់ខ្ពស់របស់ប្រទេសអាល្លឺម៉ង់បានបដិសេធមិនធ្វើសេចក្តីសន្និដ្ឋានថា ចេតនានៅក្នុងទម្រង់នៃចេតនាដោយប្រយោល នៅក្នុងរឿងក្តីទាំងឡាយដែលបទល្មើសត្រូវបានប្រព្រឹត្តឡើងដោយសហចារី គឺស្ថិតនៅខាងក្រៅផែនការដែលបានព្រមព្រៀងគ្នានោះទេ (សូមមើល Reichsgericht RGSt 44, 321; សាលក្រមចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ១៩១១ ដែលផែនការរួមគឺដើម្បីបង្ករបួសស្នាមលើរាងកាយ តែផ្ទុយទៅវិញ ចារីម្នាក់បានសម្លាប់ជនរងគ្រោះទៅវិញ)។

[៨៨] ច្បាប់ប្រទេសសូវៀតដែលនៅជាធរមានក្នុងឆ្នាំ ១៩៧៥ បានចែងថា ការប្រព្រឹត្តបទល្មើសមួយ ដោយមានការព្រមព្រៀងគ្នាជាមុន គឺជាកត្តាស្ថានទម្ងន់សម្រាប់ការផ្តន្ទាទោស (មាត្រា ៧.១ Ugolovnii Kodeks RSFSR "ក្រមព្រហ្មទណ្ឌរបស់សាធារណរដ្ឋសូវៀត" ដែលបានអនុវត្តនៅថ្ងៃទី ២៧ ខែតុលា ឆ្នាំ ១៩៦០)។ ជនដែលបង្កើត និងដឹកនាំក្រុមមួយ គឺទទួលខុសត្រូវតែចំពោះបទល្មើសដែលបានប្រព្រឹត្តឡើងដោយសមាជិកនៃក្រុមនោះ ប្រសិនបើការប្រព្រឹត្តនោះគឺជាផ្នែកមួយនៃការព្រមព្រៀងគ្នា ហើយជននោះមានបំណងឱ្យមានការប្រព្រឹត្តបទល្មើសទាំងនេះឡើង។ ក្រមព្រហ្មទណ្ឌថ្មីរបស់ប្រទេសរុស្ស៊ីបានចែងលម្អិតបន្ថែមទៀតនៅត្រង់បទប្បញ្ញត្តិនេះ ដោយកំណត់ថា អ្នកចូលរួមក្នុងការព្រមព្រៀងគ្នា មិនទទួលខុសត្រូវនូវអ្វីដែលហៅថា "ភាពហួសកំណត់របស់អ្នកប្រព្រឹត្តទេ" នៅពេលដែលចារីប្រព្រឹត្តបទល្មើសដែលសមាជិកដទៃទៀតមិនមានចេតនាឱ្យប្រព្រឹត្តនោះទេ៖ សូមមើល មាត្រា ៣០(២) មាត្រា ៣៥(៧) និងមាត្រា ៣៦ នៃ Ugolovnii Kodeks Rossiskoi Federacii (ក្រមព្រហ្មទណ្ឌរបស់សហភាពសូវៀត) ដែលបានអនុម័តដោយសភាជាន់ទាប (State Duma) កាលពីថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ១៩៩៦ និងផ្តល់ការយល់ព្រមដោយសភាជាន់ខ្ពស់ (Federation Council) កាលពីថ្ងៃទី ៥ ខែមិថុនា ឆ្នាំ ១៩៩៦។

[៨៩] ច្បាប់ប្រទេសហូឡង់មុនឆ្នាំ ១៩៨១ ចែងថា ការប្រព្រឹត្តរួមគ្នាបង្កើតបានជា ការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមប្រភេទទី ១ ដែលការប្រព្រឹត្តនេះតម្រូវឱ្យមានការចែករំលែកចេតនាគ្នានៅក្នុងសហប្រតិបត្តិការ (សូមមើល សេចក្តីសម្រេចរបស់តុលាការកំពូលប្រទេសហូឡង់ ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ១៩៨១, NJ 1983, 84/197 បានបញ្ចាក់នៅក្នុងរឿងក្តី van Sliedregt៖ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនទាំងឡាយ ចំពោះការរំលោភមនុស្សធម៌អន្តរជាតិ រោងពុម្ព TMC Asser ឆ្នាំ ២០០៣ ទំព័រ ៧៥)។

ខុសពីគ្នាជាច្រើន អំពីវិធីសាស្ត្រក្នុងចំណោមយុត្តាធិការជាតិផ្សេងៗគ្នា។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងសូមអះអាងបញ្ជាក់ អំពីការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ដែលថា ការអនុវត្តរបស់រដ្ឋនៅត្រង់ចំណុចនេះ មិនមានការឯកភាពគ្នាឲ្យបានគ្រប់គ្រាន់ដើម្បីចាត់ទុកថា វាជាគោលការណ៍ទូទៅនៃច្បាប់នោះទេ។

៣៨. ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សហព្រះរាជអាជ្ញាខកខានមិនបានបង្ហាញឲ្យឃើញថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ បង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅ

---

៩០ ពាក្យថាសហប្រព្រឹត្ត *"Co-action"* និង *"complicité"* (ដែលគ្របដណ្តប់ទាំងការជួយនិងជំរុញ និងការញុះញង់ នៅក្នុងចំណោមអំពើដទៃទៀត) គឺជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌពីរផ្សេងគ្នា ដែលមាននៅក្នុងក្រមព្រហ្មទណ្ឌរបស់ប្រទេសបារាំង។ ពាក្យថា *"Co-action"* បង្កប់ន័យនៃការចូលរួមដោយផ្ទាល់នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មជាមួយគ្នានឹងសហចារីម្នាក់ ឬច្រើននាក់ទៀត (សូមមើល មាត្រា ១២១ ដល់ ១២៧)។ ទាំងពាក្យ *"co-action"* និង *"complicité"* សុទ្ធតែបង្កប់ន័យនៃអត្ថិភាពនៃចេតនារួម ដើម្បីប្រព្រឹត្តិ ឬសម្របសម្រួលក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយ។ មិនមានទស្សនាទានណាមួយក្នុងចំណោមទស្សនទានទាំងពីរនេះ ឆ្លុះបញ្ចាំងពីការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ដូចដែលបានកំណត់និយមន័យនៅក្នុងសាលក្រមលើបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តីរបស់ *Tadić* ដោយសារថា ទស្សនាទានទាំងពីរនេះមិនរួមបញ្ចូលនូវការទទួលខុសត្រូវរបស់សហចារី ឬជនសមគំនិត ចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្រៅវិសាលភាពនៃចេតនារួមនោះទេ។ បន្ថែមលើនេះ ទស្សនទានផ្លូវច្បាប់របស់បារាំងចំពោះពាក្យ *"association de malfaiteurs"* ត្រូវបានកំណត់និយមន័យថាជា "សមាគមនៃជនទុច្ចរិត ដោយរួមមានក្រុមទាំងឡាយណា ដែលត្រូវបានបង្កើតឡើង ឬការសមគំនិតណាមួយដែលត្រូវបានបង្កើតឡើង ដើម្បីប្រព្រឹត្តិបទឧក្រិដ្ឋមួយ ឬច្រើន ដោយសកម្មភាពជាក់ស្តែងមួយ ឬច្រើន [...]"។ ទស្សនទានបែបនេះ ខុសពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ដោយសារថា *association de malfaiteurs* គឺជាបទឧក្រិដ្ឋផ្ទាល់តែម្តង ដែលមិនមែនជាទម្រង់មួយនៃការទទួលខុសត្រូវនោះទេ។ នៅក្នុងឆ្នាំ ១៩៩២ បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម ត្រូវបានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌនៅក្នុងក្រមព្រហ្មទណ្ឌរបស់ប្រទេសបារាំង ដោយរួមទាំងទម្រង់ជាក់លាក់មួយនៃ *association de malfaiteurs* ដែលមានចេតនារួមនៅក្នុងការប្រព្រឹត្តបទល្មើស។ សូមមើល ច្បាប់លេខ ៩២-៦៨២ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៩២, ឯកសារ JORF លេខ ១៦៩ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩២ ទំព័រលេខ ៩៨៧៥។

៩១ តាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ បង្ហាញថា ច្បាប់កម្ពុជាមានចែងពីទម្រង់នៃការទទួលខុសត្រូវដូចគ្នានឹងច្បាប់បារាំង ដែលក្នុងនោះ ក្រមព្រហ្មទណ្ឌនេះបានចែងអំពីការប្រព្រឹត្តរួមគ្នា និងការសមគំនិត (មើលមាត្រា ៨២-៨៧)។ ក្រមកម្ពុជានេះក៏ចែងពីបទល្មើសព្រហ្មទណ្ឌនៃ "សមាគមនៃជនទុច្ចរិត" (association de malfaiteurs) (មើលមាត្រា ២៩០)។ នៅក្នុងច្បាប់បារាំងវិញ ទម្រង់ច្បាស់លាស់នៃ "សមាគមនៃជនទុច្ចរិត" ទាក់ទងនឹងបទល្មើសប្រល័យពូជសាសន៍ បទល្មើសប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម នាពេលថ្មីៗនេះក៏ត្រូវបានចាត់ជាបទល្មើសព្រហ្មទណ្ឌនៅក្នុងច្បាប់កម្ពុជាដែរ (មើលមាត្រា ១៨៥, ១៩០ និង១៩៦ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៩)។ ទោះជាយ៉ាងណាក៏ដោយ មិនមានទម្រង់នៃការទទួលខុសត្រូវណាមួយក្នុងចំណោមទម្រង់ទាំងនេះ ឬមិនមានបទល្មើសណាមួយ (នៅក្នុងករណីនៃ "សមាគមនៃជនទុច្ចរិត") គាំទ្រដល់ការអនុវត្តទម្រង់នៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម ទម្រង់ទី ៣ ទេ (មើលលេខយោង ៩៤)។

រវាងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងកំណត់បទចោទជាថ្មីឡើងវិញ នៅក្នុងសាលក្រម នូវបទចោទប្រកាន់ដែលមាននៅក្នុងដីកាដំណោះស្រាយ ដោយបញ្ចូលសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ក្នុងករណីសមស្រប។

**ដោយយោងទៅលើមូលហេតុនានាដូចបានលើកឡើងខាងលើនេះ អង្គជំនុំជម្រះសាលាដំបូង៖**

**បដិសេធ** សំណើរបស់មេធាវីការពារក្តី ដែលចោទប្រកាន់ថា សហឧក្រិដ្ឋកម្មរួមមិនត្រូវបានលើកឡើងឱ្យបានត្រឹមត្រូវនៅក្នុងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២។

**ប្រកាស** ទទួលយកសំណើសុំរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន ៩៨ នៃវិធានផ្ទៃក្នុង។

**តម្កល់សេចក្តីសម្រេច** លើភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទម្រង់ទី២ (ដែលគេហៅថាទម្រង់មូលដ្ឋាន និងទម្រង់ជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួម) នៅក្នុងសំណុំរឿង ០០២ ដូច្នេះ បដិសេធសំណើសុំរបស់មេធាវីការពារក្តី ដែលបានចោទប្រកាន់ថា ទម្រង់ទាំងនេះនៃសហឧក្រិដ្ឋកម្មរួម មិនបង្កើតឱ្យបានជាទម្រង់នៃការចូលរួមប្រព្រឹត្តបទល្មើស ដែលត្រូវបានគេទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិទូទៅ អំឡុងរវាងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។

**កត់សម្គាល់ថា** សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ (ដែលគេហៅថាទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម) មិនបង្កើតឱ្យបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ ហើយទម្រង់នេះក៏មិនមែនជាគោលការណ៍ទូទៅនៃច្បាប់ នៅក្នុងអំឡុងពេលពាក់ព័ន្ធនឹងសំណុំរឿង ០០២ ឡើយ។

អាស្រ័យហេតុនេះ **បដិសេធ** សំណើសុំរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំឱ្យកំណត់បទចោទសាជាថ្មីនៅក្នុងសាលក្រម នូវបទចោទប្រកាន់ដែលមាននៅក្នុងដីកាដំណោះស្រាយ ដោយបញ្ចូលសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ប្រសិនបើសមស្រប។

ភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C C E T

**និល ណុន**